# សមាជចុងក្រោយនៃសង្គមរាស្ត្រនិយម

ដោយ សុទ្ធ-ប៉ូលិន

អត្ថបទដកស្រង់ចេញពីសៀវភៅ

**Cambodge - Le Chemin de l'Apocalypse**

តពីលេខមុន...

គ្មានព្រឹត្តិការណ៍អ្វីដ៏របើករបាញកើតឡើងផងដែរនៅទិវាទី២នៃសមាជ ពោលគឺថ្ងៃ២៨ធ្នូ១៩៦៩ ។ គួរកត់សំគាល់ថា បេះដូងរបស់ខ្ញុំលោតខុសសង្វាក់ធម្មតានាថ្ងៃនោះ ។ ខ្ញុំបានបោះពុម្ពផ្សាយ«ទស្សនៈរពើរវាយ»របស់ខ្ញុំសំរាប់ថ្ងៃអាទិត្យរួចហើយ... គឺអត្ថបទពីហ្វូងចៀមរបស់ Panurge ហើយសារព័ត៌មានរបស់ខ្ញុំក៏បានចែកផ្សព្វផ្សាយពេញរាជធានីរួចហើយដែរ នៅចំពេលជាមួយគ្នាដែលអត្ថបទរបស់លោកលន់-ណុន (ចុះហត្ថលេខាដោយថោង-លឹមហួង នៅក្នុងកាសែត«ប្រយោជន៍ខ្មែរ») ដែលខ្ញុំបានចាត់ទុកថា ជាគ្រាប់បែកមួយដែលរង់ចាំតែពេលវេលាសំរាប់ផ្ទុះ កំពុងតែផ្សព្វផ្សាយឥទ្ធិពលរបស់ខ្លួន ។ ខ្ញុំក៏រង់ចាំមើលសេចក្ដីច្រឡោតខឹងរបស់ស្ដេចសីហនុ ចំពោះកាសែតប្រយោជន៍ខ្មែរ... ដែលច្បាស់ជានឹងរាលដាលមកដល់សារព័ត៌មានរបស់ខ្ញុំមិនខាន ។

ខ្ញុំបានឮពាក្យចចាមអារាមដែលនិយាយថា រដ្ឋាភិបាលបានប្រើទាហានស្លៀកពាក់ជាស៊ីវិល មកបង្កប់ខ្លួនក្នុងហ្វូងសមាជ ដើម្បីធ្វើការគំរាមកំហែងចំពោះស្ដេចសីហនុ ។ ប៉ុន្តែខ្ញុំមិនបានជឿអំពីពាក្យឆ្កួតៗអស់ទាំងនេះទេ ។ បើក្រុមយោធា«ក្បត់»ទាំងនេះមិនស្លៀកពាក់ឯកសណ្ឋាននោះទេ តើគេសម្គាល់វត្តមានបានយ៉ាងដូចម្ដេចទៅ ? ម្យ៉ាងវិញទៀត តើនរណាជាមេក្រុមនៃកងទាហានបះបោរទាំងនោះ ? គឺច្បាស់ជាមិនមែនឧត្តមសេនិយលន់-នល់ទេ ដែលនៅពេលនោះពុំទាំងមានវត្តមាននៅទីក្រុងភ្នំពេញផង ។ ហើយបើពុំមានការយល់ព្រមពីលោកឧត្តមសេនិយនោះទេ តើមានទាហានខ្មែរណាម្នាក់ ហ៊ានលើកអាវុធរបស់ខ្លួនចង្អុលទៅលើព្រះប្រមុខរដ្ឋនោះ ? រឿងនេះជារឿងបំប៉ោងដែលមិនសមស្របនឹងសុភនិច្ឆ័យទាល់តែសោះ... ប៉ុន្តែតើជនណាទៅជាអ្នកផ្សព្វផ្សាយរឿងឥតសមហេតុផលដូច្នេះ ? ប្រសិនបើជាសាច់រឿងល្ខោនកំប្លុកកំប្លែងនៃ«រដ្ឋប្រហារយោធា» ដែលព្រះប្រមុខរដ្ឋទ្រង់បានបង្កើតឡើង ដើម្បីជំរុញឲ្យមហាជនខ្មែរងើបឡើងប្រឆាំងនឹងកងទ័ព គោលបំណងរបស់ស្ដេចបែបដូចនេះ មិនបានសំរេចលទ្ធផលទេ ពីព្រោះគ្មាននរណាម្នាក់យកចិត្តទុកដាក់ទាល់តែសោះ ។

កម្មវត្ថុនៃថ្ងៃទី២ គឺជាបញ្ហាមួយសំខាន់ណាស់... គឺជារឿងរំដោះវិស័យធនាគារ ដែលរដ្ឋាភិបាលស្រោចស្រង់ជាតិបានធ្វើសំណើរ ក្នុងប្រការទាក់ទាញវិនិយោគទុនបរទេសដ៏ចាំបាច់ ដើម្បីជួយស្ដួយសេដ្ឋកិច្ចនៃកម្ពុជាឲ្យចាកផុតពីរោគស្គមស្គាំងរកកលនឹងក្ស័យជីវិត ។ ម្នាក់ម្ដងៗ, ពួកវាគ្មិនដែលប្រួស្ដេចសីហនុបានងើបឡើងធ្វើសេចក្ដីថ្លែងការណ៍ ដាក់ទោសដំណើរឃ្វាងផ្លូវ (ងាកចេញពីសង្គមរាស្ត្រនិយម) របស់រដ្ឋាភិបាល ។ ប៉ុន្តែការលុបបំបាត់ជាតូបនិយកម្ម អាចចាត់ទុកថាជាឧត្តមគតិចំបង ឬក៏ជាបេសកកម្មដ៏ខ្ពង់ខ្ពស់បំផុតនៃរដ្ឋាភិបាលស្រោចស្រង់ជាតិតែម្ដង ក្នុងន័យដែលថាសម្ដេចសីហនុបានតែងតាំងរដ្ឋាភិបាលនេះឡើងក្នុងគោលបំណងស្នើសុំជំនួយអាមេរិកាំងឡើងវិញ, ប៉ុន្តែដោយទ្រង់ខ្មាស់ពាក្យសំដីខ្លួនឯង សម្ដេចក៏ចាត់តាំងលោកលន់-នល់និងទ្រង់សិរិមតៈធ្វើកិច្ចការនេះជំនួសទ្រង់វិញ ។ នៅពេលនេះ ចំកណ្ដាលសមាជតែម្ដង វាបែរជាអ្នកចូលជិតអាមេរិកាំង (តាមបញ្ជារបស់ស្ដេចសីហនុ) ក្លាយទៅជាឧក្រិដ្ឋជនទៅវិញ ។ គឺក្នុងប្រការនេះហើយដែលមហាជនខ្មែរនៅពេលនោះ ដែលពុំបានដឹងអំពីនយោបាយក្រឡិចក្រឡុចបត់បែនរបស់ទ្រង់ ក៏លែងយល់អ្វីទាំងអស់ ហើយក្លាយទៅជាជញ្ជាំងគរ ជញ្ជាំងថ្លង់ ចំពោះពាក្យសំដីរំអួយម្ទេរម៉្ទររបស់ព្រះប្រមុខរដ្ឋ ។

គួរកត់សម្គាល់ថា ពួកវាគ្មិនដែលស្ម័គ្រចិត្តមកស្រែក«ហៃអើ!»ឲ្យស្ដេចសីហនុ សុទ្ធសឹងតែពួកស្រទាប់ក្រោម ពួកអ្នករាជការតូចតាចដែលមកពីខេត្ត ។ ពួកឥស្សរជនគ្រាក់ៗនៃសង្គមរាស្ត្រនិយម មានទ្រិញ-វ៉ាញនិងអ៊ិន-តាំជាដើមត្រូវស្ងាត់មាត់ដូចគេចុក ។ អ្នកទាំងពីរនាក់នេះនៅខាងរដ្ឋាភិបាល ប៉ុន្តែពួកគេមានការភ័យខ្លាចមិនហ៊ានបញ្ចេញយោបល់ទេ ។ ចំណែកនៅខាងទ្រង់សិរិមតៈវិញ មានវាគ្មិនម្នាក់ដ៏អង់អាច គឺលោកឱប-គឹមអាង រដ្ឋមន្ត្រីខាងផ្នែកសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលហ៊ានការពាររដ្ឋាភិបាលតែម្នាក់ឯង តទល់នឹងអង្គសមាជទាំងមូល ។ ដោយសារតែថ្វីមាត់របស់លោកពេញមួយថ្ងៃ (នៃទិវាទី២) លោកឱប-គឹមអាងក៏បានទទួលជោគជ័យ ក្នុងប្រការឲ្យអ្នកផងទទួលយកសេដ្ឋកិច្ចនៃផ្សារសេរី ជាភ័ព្វសំណាងចុងក្រោយ ដើម្បីជួយស្រោចស្រង់កម្ពុជា ឲ្យរួចផុតពីការស្ទះដង្ហើមថប់ខ្យល់ក្នុងវិស័យសេដ្ឋកិច្ច ។

⌘

⌘ ⌘

នៅព្រឹកថ្ងៃទី៣ ប្រមាណម៉ោង១១ គេហាក់ដូចជាឃើញថា អ្វីៗក៏ត្រូវមានការបញ្ចប់ដោយមានជោគជ័យខាងរដ្ឋាភិបាលដែរ ។ ខ្ញុំមានសេចក្ដីធូរស្រាលយ៉ាងច្រើនក្នុងទ្រូង... ប៉ុន្តែក៏នៅហាក់ដូចជាមិនទាន់អស់ចិត្តសោះ ពីព្រោះខ្ញុំឃើញថាសភាពការណ៍ដូចជាវាងាយស្រួលពេកហើយ ។ គឺដោយមកពីមូលហេតុដែលខ្ញុំមានជំនឿថា ព្រះប្រមុខរដ្ឋមិនមែនសុខចិត្តចុះចាញ់ដោយងាយស្រួលដល់ម្លឹងពេកនោះទេ ។ គឺជាព្រឹត្តិហេតុមួយដ៏អស្ចារ្យណាស់ ! សម្ដេចសីហនុកំពុងទទួលយកបរាជ័យរបស់ទ្រង់នៅក្នុងសភាពកិត្តិយស ពោលគឺទ្រង់កំពុងតែផ្ដល់ដំបូន្មានដល់រដ្ឋាភិបាល ឲ្យធ្វើដំណើរដោយប្រយ័ត្នប្រយែងនៅតាមមាគ៌ានៃសេដ្ឋកិច្ចសេរី ។ ក្នុងមួយរំពេច ក៏ស្រាប់តែការយលសប្តិអាក្រក់បានផ្ទុះឡើង...ចំណែកប្រផ្នូលរបស់ខ្ញុំក៏បានក្លាយទៅជាការពិត ។ វាគ្មិនម្នាក់ឈ្មោះ ហៃម-វណ្ណបុទ្ធិ (★★ នៅពេលនោះខ្ញុំកំពុងតែស្ដាប់ការវិភាគតាមវិទ្យុ, ប៉ុន្តែធ្លាប់ស្គាល់ជនម្នាក់នេះច្បាស់ណាស់ ។ គឺជាជនជាតិខ្មែរម្នាក់ ដែលមានដើមកំណើតយួន មានសំបុរស្រអែម មុខស្រួចចំអឹង ប្រកបដោយសក់រួញអង្ការដី ។ ជននេះធ្លាប់បានជួលបន្ទប់មួយនៅក្រោមផ្ទះរបស់ខ្ញុំ ។ នៅក្នុងឆ្នាំ១៩៦៥ ជននេះធ្លាប់បានយកដី-សទៅលក់ឲ្យវិទ្យាល័យ«មហាសាល»របស់លោកថាច់-ណាំង, ដែលនៅទីនោះខ្ញុំធ្លាប់បានបង្រៀនទស្សនវិជ្ជាដល់សិស្សថ្នាក់បញ្ចប់ ។ ហៃម-វណ្ណបុទ្ធិ ដែលជាក្មួយម្នាក់របស់ប្រពន្ធសុស្ដែន-ហ្វេរណង់ដែស ក៏ឡើងលើវេទិកា ហើយធ្វើឲ្យមានការភ្ញាក់ផ្អើលស្រឡាំងកាំង (ដល់ប្រទេសកម្ពុជាទាំងមូល) ដោយបានលាតត្រដាងនូវអំពើ«យប់ឃិតក្បត់មួយ» ដែលមានធ្វើឡើងប្រឆាំងនឹងព្រះប្រមុខរដ្ឋ ។ «អំពើក្បត់នោះមានស្ថិតនៅក្នុងអត្ថបទមួយប្រកបដោយពិសពុលអស្ចារ្យ», ហៃម-វណ្ណបុទ្ធិពោល «ដែលចោទថាអនាធិបតេយ្យនិងបរាជ័យសេដ្ឋកិច្ច គឺបណ្ដាលមកពីការដឹកនាំមិនល្អនៃសង្គមរាស្ត្រនិយមរបស់សម្ដេចសីហនុ» ។

សមាជតិទាំងមូលមានការភិតភ័យរន្ធត់ញាប់ញ័រ។ នៅពេលនោះអ្វីៗក៏ត្រូវបានរើកកាយបកអាក្រាត បញ្ចេញពោះវៀនពោះតាំងមកខាងក្រៅគ្មានសល់អ្វីទេ ទាក់ទងនឹងការឃុបឃិតក្បត់និងរដ្ឋប្រហារដ៏មហាអាថ៌កំបាំងនេះ ។ ជនណាក៏ដោយ ដោយរាប់ទាំងសម្ដេចសីហនុឡើងទៅ ដែលអះអាងទៅថ្ងៃមុខថា ខ្លួនមិនបានដឹងអ្វីសោះពីការឃុបឃិតក្បត់នេះ គឺជាជនកុហកភូតភរ ។ ហៃម-វណ្ណបុទ្ធិពោលមិនទាន់ផុតពីមាត់ផង ក៏ស្រាប់តែនុត-ឈឿមឡើងលើវេទិកាផងដែរ ហាក់ដូចជាចង់ដណ្ដើមមេក្រូមកនិយាយ ដោយប្រើកម្លាំងបាយតែម្ដង (★★★នុត-ឈឿម ចាងហ្វាងសារពត៌មាន«សុជីវធម៌» បោះផ្សាយ២០,០០០ច្បាប់... ប៉ុន្តែនៅពេលចុងក្រោយនេះ នុត-ឈឿមបានចាញ់ប្រាក់រាប់លានទៅកាស៊ីណូអស់ទៅហើយ)

នរណាៗក៏មើលឃើញផងដែរ ថាជនពីរនាក់នេះជាគូកននឹងគ្នា (នុត-ឈឿមហើយនិងហែម-វណ្ណបុទ្ធិ) ។ ខ្ញុំមានអារម្មណ៍ថា អ្នកទាំងពីរនេះជាពួក Pieds Nickelés ដែលធ្វើនយោបាយ ពោលគឺអាឡេវនិងអាជ័យមេរតចូលហ៊ុនគ្នា ចំណែករដ្ឋប្រហារនេះជារឿងក្បត់ជាតិ ដែលមានរបៀបលក្ខណៈជា Mickey Mouse នៅ Disney Land ។ ស្តេចសីហនុហើយនិងស្តេចសិរិមតៈមិនហ៊ានបុកទង្គិចគ្នាដោយចំហទេ ម្ល៉ោះហើយក៏បញ្ជូនពួកជនស្រទាប់ក្រោម ពួក Pieds Nickelés ឲ្យប្រយុទ្ធគ្នាជំនួសទ្រង់វិញ ៖ មានលឿង-វ៉ើន (ចាងហ្វាងប្រយោជន៍ខ្មែរ) ថោង-លឹមហួង, ហែម-វណ្ណបុទ្ធិ, នុត-ឈឿម...។

បុរសចុងក្រោយនេះ ដែលជាកំពូលអ្នកបញ្ចើចបញ្ចើរចំពោះរបបសីហនុ ក៏ចាប់ផ្តើមថ្លែងសង្កថា ប្រកបដោយគារវកិច្ចនិងសេចក្តីគោរពដ៏ជ្រាលជ្រៅចំពោះព្រះប្រមុខរដ្ឋ ជាពិសេសបានសំដែងនូវភក្តីភាពគ្មានរង្គោះរង្គើរចំពោះព្រះអង្គ រួចហើយក៏បញ្ចេញស្នៀតញ៉ីកវាយប្រហារទៅលើរដ្ឋាភិបាល ៖

«ទូលព្រះបង្គំខ្ញុំបាទ នុត-ឈឿម, ជាចាងហ្វាងសារពត៌មានសុជីវធម៌ ជាកូនចៅដ៏ស្មោះត្រង់នៃសង្គមរាស្ត្រនិយម ជាព្រះរាជបំរើដ៏មានកត្តញ្ញូតាធម៌ដ៏ក្រៃលែងចំពោះព្រះប្រមុខរដ្ឋ សូមសម្តេចឪជាអម្ចាស់មេត្តាករុណាលើកលែងទោសឲ្យទូលព្រះបង្គំខ្ញុំបាទ ដែលហ៊ានលើករឿងមួយដ៏ធំមកនៅពេលនេះ... ប៉ុន្តែនៅពេលដែលព្រះអគ្គមគ្គុទ្ទេសក៏ដ៏ជាទីសក្ការៈរបស់យើងបានខំប្រឹងបំពេញបេសកកម្មឥតសំចៃព្រះកាយ ដោយចំណាយព្រះអង្គនិងព្រះសុខុមាលភាព ដើម្បីផ្តល់ជូនមាតុប្រទេស នូវជោគជ័យដ៏មហារុងរឿង ទាំងផ្នែកនយោបាយសេដ្ឋកិច្ច និងផ្លូវទូត... វាមានពួកជនខ្លះដែលមិនសប្បាយចិត្តទាល់តែសោះ នៅក្នុងលក្ខណៈណាដែលពួកគេមិនបានផ្តួលព្រលំរាជសង្គមរាស្ត្រនិយមរបស់សម្តេចឪ ។ ជាឧទាហរណ៍ វាមានជនខ្លះដូចឈ្មោះ លឿង-វ៉ើន នៅក្នុងកាសែតប្រយោជន៍ខ្មែរ ដែលច្បាស់ជាជនថោកទាបម្នាក់លក់ខ្លួនបំរើផលប្រយោជន៍ចក្រពត្តិនិយម ដែលតែងតាំងខ្លួនជាចៅក្រម ហ៊ានអារកាត់ព្រះរាជបេសកកម្មនៃសម្តេចព្រះប្រមុខរដ្ឋ ។ យោងតាមយោបល់របស់ជននេះ អន្តរាគមន៍របស់រដ្ឋដើម្បីទទួលបន្ទុកនូវសេដ្ឋកិច្ចជាតិ ដែលជាព្រះតម្រិះភ្លឺស្វាង ពោរពេញដោយសុភនិច្ឆ័យរបស់សម្តេច... វាបែរទៅជាពន្លិចប្រជាជាតិរបស់យើង ឲ្យធ្លាក់ទៅក្នុងសភាពមហាហិនហោចទៅវិញ» ។ ហើយនុត-ឈឿមក៏បានអានអត្ថបទមួយភាគនៅក្នុងសារពត៌មានប្រយោជន៍ខ្មែរមុននឹងធ្វើសេចក្តីបញ្ចប់ ៖ «...សម្តេចជាអម្ចាស់ បញ្ហានេះជារឿងពានរាំងមួយដ៏ធ្ងន់ធ្ងរណាស់ ទូលព្រះបង្គំសូមព្រះរាជទានអនុញ្ញាតស្នើរព្រះអង្គឲ្យដាក់ទោសដល់ជនក្បត់ថោកទាប ជនកំសាកឈ្មោះ លឿង-វ៉ើន ដែលប្រហែលគ្រាន់តែជាកូនជីងតូចមួយនៃខ្សែរយៈដ៏ធំធេងនៃពួកជនក្បត់... ដើម្បីផ្តល់ជាគំរូដល់ប្រជាជាតិយើងទាំងមូល កុំឲ្យមានជនណាទៀតហ៊ានងើបឡើងបំផ្លិចបំផ្លាញមាតុប្រទេស បំផ្លាញសង្គមជាតិ និងអង្គសម្តេចឪព្រះអគ្គមគ្គុទ្ទេសក៍ ដ៏ជាទីគោរពបូជារបស់យើង ។ គឺដោយទូលព្រះបង្គំខ្ញុំបាទយល់ថា... តែម្នាក់វា ជននេះមិនហ៊ានបោះពុម្ពផ្សាយអត្ថបទបែបដូចនេះទេ...» ។

ភ្លាមបន្ទាប់ពីអន្តរាគមន៍របស់នុត-ឈឿម សម្តេចសីហនុក៏បានផ្ទុះនូវកំហឹងក្រេវក្រោធមួយដែលគេមិនអាចអធិប្បាយ ។ ទ្រង់លែងមានលក្ខណៈជាបុរសទៀតហើយ តែគឺជាស្ត្រីភេទម្នាក់ដែលឆ្កួតនឹងសេចក្តីប្រច័ណ្ឌ ឬដូចជាខ្លាញីរបួស ដែលកំពុងតែកើតរោគក្រពុលឈាមកាចសាហាវ ។ ដោយសម្លេងញ៉េវៗឡើងខ្ពស់គ្រលួច សម្តេចព្រះប្រមុខរដ្ឋបានថ្លែងថា បន្ទាប់ពីបានធ្វើពលិកម្មដ៏សន្ធឹកសន្ធាប់ចំពោះប្រទេសជាតិ ទ្រង់មានសេចក្តីហត់នឿយជាពន់ពេកក្រៃ ។ ពួកអ្នកនយោបាយស្តាំនិយមមិនចាំបាច់ធ្វើការចំអកចំពោះទ្រង់ ដោយបោះពុម្ពផ្សាយអត្ថបទដៀមដាមបែបនេះទេ ពីព្រោះទ្រង់ពុំមានជាប់ចិត្តនឹងអំណាចទាល់តែសោះ ហើយថាទ្រង់នឹងធ្វើដំណើរចាកចេញពីអំណាចមួយរំពេច ល្អឹកណាបើជនស្តាំនិយមទាំងនេះធ្វើសំណើរចំពោះទ្រង់ដោយគ្មានលាក់លៀម ។ «ខ្ញុំព្រះកូណាខ្ញុំមានសេចក្តីហត់នឿយខ្លាំងណាស់ អំពីអ្វីៗគ្រប់សព្វទាំងអស់... ហត់នឿយនឹងសេចក្តីរមិលគុណដ៏ខ្មៅងងិត... ហត់នឿយនឹងបញ្ហារបស់រដ្ឋ ដែលបានចោទឡើងជាទម្ងន់អំរែក មិនអនុញ្ញាតឲ្យខ្ញុំព្រះកូណាខ្ញុំ មានជីវិតសុខសប្បាយទៅបាន ។ ខ្ញុំព្រះគូណាខ្ញុំមានជំនឿថា បានធ្វើពលិកម្មអស់ទាំងកម្លាំងកាយកម្លាំងចិត្តនិងបញ្ញា ដើម្បីបំរើប្រជាជាតិជាទីស្រឡាញ់ និងប្រជារាស្ត្រតូចតាច ដែលបានប្រគល់សេចក្តីទុកចិត្តមកលើខ្ញុំព្រះកូណាខ្ញុំ... ខ្ញុំព្រះកូណាខ្ញុំមិនសមនឹងទទួលសំណងគុណនៃអកត្តញ្ញូតាធម៌បែបដូចនេះទេ ។ ខ្ញុំព្រះកូណាខ្ញុំ គួរតែដកថយចេញពីទីនេះ... ពីព្រោះថាជាចំណង់របស់អ្នកនយោបាយពីគ្រប់ទិសទី», ទ្រង់ស្រែកដំអូញដោយសម្លេងស្រួយស្រេះ ប្រៀបបាននឹងមនុស្សខ្មោចចូល ។

ដូចសព្វដងដែលស្តេចសីហនុច្រឡោតខឹង ប្រជាជាតិខ្មែរទាំងមូលមានសេចក្តីភិតភ័យតក់ស្លុតតក្កមា ។ អ្នកផងហាក់ដូចជាបានស្ថិតនៅក្នុងប្រាសាទ«គក់ទ្រូង» ។ ដោយឮសម្លេងឈឺផ្សារក្រហាយដូចគេដាច់ស្បែកបែបនេះ នរណាៗក៏ចង់រត់ទៅលាក់ខ្លួនពួនសម្ងំផងដែរ ។ រូបខ្ញុំដែលកំពុងតែស្តាប់វិទ្យុ, ខ្ញុំដឹងខ្លួនថាកំពុងតែភ័យឡើងស្លុតស្រយង់រូបកាយ ។ ខ្ញុំកំពុងតែនឹកទៅដល់វាសនាអភ័ព្វនៃមិត្តរបស់ខ្ញុំ ថោង-លឹមហួង ដែលកំពុងតែចង់រត់ទៅឆ្ងាយសែនឆ្ងាយពីសមាជជាតិ ហើយខ្លួនខ្ញុំក៏ធ្លាក់ទៅក្នុងក្តីអស់សង្ឃឹម ដោយមិនដឹងថាត្រូវជួយមិត្តភក្តិរបស់ខ្ញុំដោយប្រការណាបាន ។ ខ្លួនខ្ញុំផ្ទាល់ក៏នឹកឃើញថា នាទីចុងក្រោយរបស់ខ្ញុំបានមកដល់ផងដែរ ។ ខ្ញុំដឹងច្បាស់ណាស់ថា សម្លេងមេក្រូជាអាវុធមួយដ៏មហិមាដ៏មហាបិសាច ប្រកបដោយប្រសិទ្ធិភាពជាទីបំផុត របស់សម្តេចព្រះប្រមុខរដ្ឋ ហើយក្នុងប្រការនេះ គ្មានជនណាម្នាក់អាចទប់ទល់នឹងព្រះអង្គបានឡើយ ។ រាល់ពេលដែលសម្តេចធ្វើសង្គ្រាមនៃពាក្យសំដី ដែលពោរពេញទៅដោយពិសពុលនៃគំនុំសងសឹក ដែលទ្រង់បាញ់ចេញទៅដូចគ្រាប់មីត្រៃយើ ដោយបង្វិលក្បាលមេក្រូរបស់ទ្រង់រេចុះឡើង ប្រហែលគ្នានឹងគេបាញ់រះទៅលើខ្មាំងសត្រូវក្នុងទីលានប្រយុទ្ធ ប្រជាជនខ្មែរម្នាក់ៗត្រូវស្ថិតនៅក្នុងសភាពតក់ស្លុតញាប់ញ័រដូចកូនសត្វ ។ នៅពេលនោះខ្ញុំមានជំនឿប្រាកដក្នុងចិត្តថា សម្តេចសីហនុនៅតែមានលក្ខណៈជាអ្នកឈ្នះ ជាជ័យលាភី ជាជើងឯកម្តងទៀតនៃពួកក្រុមវាគ្មិនសមាជជាតិ គឺដូចតែសព្វដង ។ ប៉ុន្តែក្នុងរំពេជនោះ ខ្ញុំស្រាប់តែលែងឮសម្លេងរបស់ទ្រង់ ឮតែសម្លេងអនាធិបតេយ្យដូចជាកៅអីរលំ ដែលបណ្តាលមកពីមនុស្សរត់ប្រសេចប្រសាចជាដើម ឬក៏ជាសម្លេងក្រោកក្រាកនៃឧឃោសនស័ព្ទដែលរិតមិនត្រូវ ? ។ ឬក៏ជាសម្លេងអ្វីផ្សេងទៀតក៏ពុំដឹង ប៉ុន្តែខ្ញុំមានសេចក្តីភិតភ័យតក់ស្លុតពន់ប្រមាណ ខ្ញុំក៏ពុំបានធ្វើការវិភាគអំពីប្រភពនៃសម្លេងទាំងនោះឡើយ ។ រួចហើយក៏មានបរិយាកាសស្ងាត់សូន្យឈឹងតែម្តង។ វិទ្យុជាតិលែងធ្វើការផ្សាយបន្ត ។ សមាជជាតិក៏ត្រូវបញ្ឈប់ចោលដោយគ្មានសេចក្តីបញ្ចប់ ។

ខ្ញុំបានដឹងនៅពេលបន្តិចក្រោយមក ថាសម្តេចសីហនុបានដកថយខ្លួនជាប្រញាប់ប្រញាប់ទៅវិមានរដ្ឋចំការមន ។ ខ្ញុំបានឮថា ទ្រង់មានការភិតភ័យខ្លាចក្រែងមានរដ្ឋប្រហារមួយកំពុងតែកើតឡើង ហើយថាទ្រង់មានជំនឿពិតមែនទៅលើវត្តមាននៃពួកក្រុមឃាតដែលស្លៀកពាក់ជាស៊ីវិល ហើយដើររ៉េរ៉ៃនៅក្នុងវាលមេរុក្នុងប្រការធ្វើការគំរាមកំហែងទៅលើរូបកាយរបស់ព្រះប្រមុខរដ្ឋ ។ គឺហេតុដូច្នេះហើយបានជាទ្រង់បានចាកចេញទៅកណ្តាលសង្កថាមួយ ដែលទ្រង់មិនបានបញ្ចប់ ។

ទោះជាយ៉ាងណាក៏ដោយ នៅរសៀលថ្ងៃច័ន្ទ៣០ធ្នូ១៩៦៩ ថ្ងៃចុងក្រោយនៃសមាជរបស់«សង្គមរាស្ត្រនិយម» លោកស័ក្តិប្រាំសុសស្តែន-ហ្វែរណង់ដែស រដ្ឋមន្ត្រីក្រសួងប៉ូលិសបានប្រើសមត្ថកិច្ចផ្ទាល់ខ្លួនរបស់លោក (Autorité personnelle) ដើម្បីចាប់ខ្លួនលោកលឿង-វ៉ើនយកមកឃុំទុក ហើយបញ្ជូនមនុស្សរបស់លោកដេញតាមចាប់ ថោង-លឹមហួង ដែលទើបនឹងបាត់ខ្លួន (ខ្ញុំបានឃើញថោង-លឹមហួងឡើងវិញ ជិតបីខែក្រោយមកប៉ុណ្ណោះ) ។ តើលោកសុស្តែនមានដឹងទេថា អត្ថបទដែលផ្សាយចុះក្នុង«ប្រយោជន៍ខ្មែរ» គឺចេញមកពីអ្នកអង្គម្ចាស់សិរិមតៈអង្គឯង ដែលត្រូវជាចៅហ្វាយនាយផ្ទាល់របស់លោក ? ខ្ញុំក៏បានដឹងជា

មួយគ្នាផងដែរ ថាលោកសក្តិប្អូនលន់-ណុន ក៏បានរត់ប្រាស់អាយុផងដែរ, ដោយភ័យខ្លាចគំនុំសងសឹករបស់ព្រះប្រមុខរដ្ឋ ដើម្បីទៅលាក់ខ្លួននៅខេត្តកំពង់ស្ពឺ ។ ខ្ញុំហាក់ដូចជាដឹងថា រដ្ឋាភិបាលស្រោចស្រង់ជាតិនឹងត្រូវរលាយដូចក្រមួនត្រូវថ្ងៃ ចំណែកទ្រង់សិរិមតៈគឺគ្រាន់តែជាជនអភ័ព្វម្នាក់ដ៏គួរឲ្យអាណិតអាសូរ ។ ខ្ញុំហាក់ដូចជាបាត់បង់សេចក្តីសង្ឃឹមអស់រលីង ។

ក៏ប៉ុន្តែខុសពីការស្មានរបស់ខ្ញុំ, នៅថ្ងៃស្អែកឡើងស្រាប់តែសម្តេចសីហនុរត់ទៅចូលពេទ្យកាល់ម៉ែត ដែលជាមន្ទីរពេទ្យបារាំងតែមួយនៅទីក្រុងភ្នំពេញ ដោយទ្រង់មានលក្ខណៈជាមនុស្សមមើមមាយ, យោងតាមកសិណសាក្សីខ្លះ, ដែលស្លៀកពាក់មិនជាបើ ប្រហាក់ប្រហែលគ្នានឹងអ្នកទោសនយោបាយ ដើម្បីព្យាបាលជម្ងឺមួយ (ជម្ងឺសតិអារម្មណ៍) (crise nerveuse) ដែលធ្លាក់មកដល់ខុសពេលវេលា (ខុសពេលវេលា ពីព្រោះដោយហេតុថា វត្តមានរបស់ទ្រង់នៅលើឆាកនយោបាយកម្ពុជា នឹងអាចដោះស្រាយនូវវិបត្តិគ្រប់យ៉ាងទាំងអស់ ក្នុងប្រការដែលថាពួកអ្នកប្រឆាំងនឹងទ្រង់ មានការភ័យខ្លាចចំពោះព្រះអង្គពេកណាស់ ហើយក៏គ្មាននរណាម្នាក់ ដែលមានទម្ងន់នយោបាយគ្រប់គ្រាន់ ដើម្បីទប់ទល់នឹងព្រះអង្គដែរ ) ។ ប៉ុន្តែវាបែរជាសម្តេចមានត្រចៀក-សជាងពួកយើងទៅទៀត ។ សម្តេចព្រះមគ្គទ្វេសក៍ដ៏ឆ្នើម ហាក់ដូចជាស្រមោលខ្លួនឯង... ហាក់ដូចជាខំប្រឹងរត់គេចចេញពីសម្បជញ្ញៈខ្លួនឯង ។

⌘

⌘ ⌘

ប្រសិនបើគេយល់ថា មានរដ្ឋប្រហារឃោធាបំរុងកើតឡើងនៅពេលនោះមែន ព្រឹត្តិការណ៍ដែលបង្ហាញពីស្តេចសីហនុរត់មកព្យាបាលនៅក្នុងមន្ទីរពេទ្យបែបដូចនេះ របៀបជាជនអាក្រាតនិងដោយចំហជាទីបំផុត ដែលនៅទីនោះព្រះអង្គអាចទទួលរងគ្រោះបាន១០០ដង លើសពីប្រការដែលទ្រង់ស្ថិតនៅក្នុងវិមានរដ្ឋចំការមន ដែលមានកំផែងខ្ពស់ការពារ និងព្រៃព្រឹក្សាដុះច្រូងច្រាង ព្រមទាំងមានអង្គរក្សប្រដាប់ដោយអាវុធពេញខ្លួនចាំយាមពីគ្រប់ច្រកល្ហក... គឺគ្រាន់តែបានធ្វើឲ្យសម្តេចលេចឡើងជាជនកំប្លុកកំប្លែង ។ ជាការពិត ប្រសិនបើទ្រង់ភ័យខ្លាចមានការព្យាបាទមកលើរូបកាយពិតមែន... ហេតុអ្វីបានជាទ្រង់ចេញមកបង្ហាញខ្លួនជាចំណីរបស់ពួកឃាតករយ៉ាងស្រួលម្ល៉េះ ? នៅទីបំផុតស្តេចសីហនុមានការភ័យខ្លាចចំពោះការស្តីបន្ទោស ពីសំណាក់សតិសម្បជញ្ញៈរបស់ខ្លួនឯងទៅវិញសោះ។ រដ្ឋប្រហារនេះវាស្ថិតនៅក្នុងការស្រមើស្រមៃរវើរវាយ និងអំពើឆ្កួតលីលារបស់ទ្រង់តែប៉ុណ្ណោះ ។ ទ្រង់បានឆ្អែប្រឌិតរដ្ឋប្រហារនេះឡើង ដើម្បីធ្វើជាលេសបន្ធូរសម្បជញ្ញៈរបស់ខ្លួនឯង ពីព្រោះទ្រង់ដឹងច្បាស់ណាស់ថា ទ្រង់កំពុងរៀបចំប្រព្រឹត្តអំពើសាមាន្យមួយ ដែលមិនអាចអត់ទោសឲ្យបាន ។ សម្តេចកំពុងរៀបចំរត់ទៅបរទេស ម្ល៉ោះហើយព្រះអង្គត្រូវតែឆ្អែប្រឌិត«ពួកក្រុមឃាតករ» ។ ទ្រង់កំពុងរៀបចំរត់ទៅចូលពិភពកុម្មុយនិស្ត ព្រមទាំងក្បត់ប្រជាជាតិខ្លួនឯង, ម្ល៉ោះហើយវាត្រូវតែទ្រង់បន្ធូរសតិសម្មជ់ញ្ញៈរបស់ទ្រង់ ដោយស្វែងរកលេសមួយឲ្យសមស្របនឹងអំពើឧក្រិដ្ឋរបស់ខ្លួន ។ ល្បែងដឹកនាំរឿងរដ្ឋប្រហារវាមានរួចទៅហើយ នៅក្នុងភាពយន្តចុងក្រោយរបស់ទ្រង់ ៖ «សន្និប្រកាស» (ឬព្រះសូរិយាអស្តង្គត!) ហើយនៅក្នុងពេលនោះ សិល្បៈបិសាចដដែលនេះកំពុងរំសាយចេញមកក្នុងសេចក្តីពិត ដូចជារុស្សីរ៉ូវធាក់ចេញមកពីស្ថាននរក ។ សម្តេចសីហនុ ក្នុងឋានៈជាអ្នកដឹកនាំភាពយន្ត បានចាត់ខ្លួនលោកជា Shakespeare ។ ដោយវង្វេងវង្វាន់ទៅក្នុងសុបិន្ត<រ៉ូម៉ង់ទឹក> ព្រះអង្គបានចាត់ទុកវាំងចំការមនរបស់ទ្រង ជាប្រាសាទ Hollywood (Hollywood ជាប្រាសាទស្តេចនៅក្នុងរឿង Mc Beth របស់ Shakespeare) ចំណែកលោកឧត្តមសេនិយលន់-នល់ ឬអ្នកអង្គម្ចាស់ស៊ីសុវត្ថិ-សិរិមតៈ បានត្រូវចាត់ទុកជា «ឃាតករ» Mc Beth ។ ទៅថ្ងៃមុខទៅ សម្តេចបានថ្លែងប្រាប់ពួកអ្នកសារពត៌មានជាច្រើនគ្នាថា ដំណើរជីវិតរបស់ទ្រង់ «មានលំនាំទ្រង់ទ្រាយដូចសោកនាដកម្មរបស់ Shakespeare បេះបិទ ។ សម្តេចដឹងច្បាស់ណាស់ថា ព្រះអង្គកំពុងរៀបចំបង្កើតរដ្ឋប្រហារដ៏អប្រិយមួយពោរពេញដោយឈាម ប្រឆាំងនឹងប្រជាជាតិនិងប្រជារាស្ត្ររបស់ខ្លួនឯង ។ គឺហេតុដូច្នេះហើយបានជា ព្រះអង្គមានអាកប្បកិរិយាស្កន់ជាន់ប្រទ្រុះប្រទ្រះ ដូចសត្វល្អិតដែលជាប់នៅក្នុងក្នុងសំណាញ់ពីងពាង គឺសភាពកន្ទ្រឹងកន្ទ្រើងនៃប្រមុខរដ្ឋមួយអង្គ ដែលមានដំណើររវោអន្ទះសារដូចមនុស្សប្រមឹក ។ ជាការពិតណាស់ សម្តេចមានការភ័យខ្លាចរអារខ្លាចក្រែងប្រជារាស្ត្រខ្មែរដឹងយល់ពីពោះវៀនបត់ចន្លាស និងពីគំនិតពិតប្រាកដដ៏មហាស្មោគគ្រោករបស់ទ្រង់ ។ ត្រង់ចំណុចនេះ ព្រះអង្គមិនគួរមានការភ័យខ្លាចសោះ ជនជាតិខ្មែរគ្រប់ៗរូប ដោយចាប់ផ្តើមពីលោកលន់-នល់និងទ្រង់សិរិមតៈ ព្រមទាំងរូបខ្ញុំផ្ទាល់ នៅតែងាប់ក្រឡាជាប់មន្តស្នេហ៍របស់ទ្រង់ដ៏ផ្តាប់មុខ ។ បើទោះជាពួកគេដឹងថាព្រះអង្គបានប្រព្រឹត្តអំពើឧក្រិដ្ឋច្រើនយ៉ាងណា ក៏នៅតែមិនប្រកែប្រកាន់នឹងទ្រង់មែនទែន ។ ប៉ុន្តែមានរឿងមួយ ដែលជនជាតិខ្មែរម្នាក់ៗមិនមានមន្ទិលសង្ស័យទៅលើទ្រង់សូម្បីប៉ុនសរសៃសក់ គឺរឿងភក្តីភាពឬសេចក្តីស្មោះត្រង់ ដែលទ្រង់មានចំពោះប្រទេសកម្ពុជា ។ នរណាៗតែងនឹកស្មានផងដែរថាស្តេចខ្មែរតែងតែស្រឡាញ់ទឹកដីខ្មែរ !!

ឬមួយ ឬមួយរដ្ឋប្រហារនេះ វាមានពិតប្រាកដមែន តែមានតែនៅក្នុងសន្តានចិត្ត (!!) ។ យើងខ្មែរច្រើនគ្នាកាលសម័យនោះ ចង់ពិឃាតឪពុកខ្លួនឯងពិតមែនតែមិនហ៊ានទទួលស្គាល់ថាជាអំពើក្បត់ ម្ល៉ោះហើយក៏មើលមិនឃើញអំពើក្បត់ដ៏ពិតប្រាកដរបស់ឪពុក ដែលហ៊ានសម្លាប់កូនចៅខ្លួនឯង ??

សម្តេចសីហនុសំរាកនៅក្នុងមន្ទីរពេទ្យបាន២-៣ថ្ងៃ រួចហើយក៏វិលត្រឡប់ទៅវាំងចំការមនវិញ ក្នុងប្រការប្រមែប្រមូលឥវ៉ាន់ឥវ៉ាន់ ហិបហោញ រៀបចំចេញដំណើរ ។ ជំនឿថាមានរដ្ឋប្រហារក៏បានរាលដាលដូចជម្ងឺឆ្លង ទៅដល់ពួកសហការីដែលនៅជុំវិញព្រះអង្គ ព្រមទាំងទៅដល់ប្រជាជាតិទាំងមូល ។ ព្រះរាជបំរើមួយក្រុមដ៏ចម្លែកនឹងរៀបចំដង្ហែទ្រង់ទៅទីក្រុងប៉ារីស, ម៉ូស្គូ និង ប៉េកាំង ៖ គឺនុត-ឈឿម ដែលបានលះបង់សារពត៌មានរបស់ខ្លួន, ប៉ែន-នុត អតិតនាយករដ្ឋមន្ត្រីដែលចាំតែស្រែក«ហៃអើៗអាជ័យធ្លាក់ទឹក!», Alain Daniel លេខាធិការពិសេសរបស់ទ្រង់ដែលមានសញ្ជាតិជាបារាំង ។ កាលនោះ លោកម៉ាលី-ហៃដែលមាននាទីជាអ្នកត្រួតពិនិត្យនៅសាខាក្រសួង Valises diplomatiques នៃកិច្ចការបរទេស បានរាប់មើលវ៉ាលីសរបស់ព្រះប្រមុខរដ្ឋនិងព្រះរាជបរិវាររបស់ទ្រង់ឃើញថាមានចំនួន៥២វ៉ាលីស ។ ក្នុងព្រះរាជដំណើរធម្មតារបស់សម្តេច មានវ៉ា-លីសតែ១០ប៉ុណ្ណោះ ។ «អស្ចារ្យណាស់ !», លោកម៉ាលី-ហៃលាន់មាត់ដោយហួសចិត្ត «បើសម្តេចចាកចេញទៅដោយមាន៥២វ៉ាលីស គឺមានតែព្រះអង្គបំរុងធ្វើដំណើរដោយឥតវិលត្រឡប់» ។

ជាការពិតសម្តេចត្រូវចាកចេញពីប្រទេសកម្ពុជា ដោយមានការល្ងើងជូរចត់នៅក្នុងចិត្ត ។ លោកនាយករដ្ឋមន្ត្រីប្រតិភូ ទ្រង់សិរិមតៈ បានធ្វើឲ្យខូចខាតដល់ផលប្រយោជន៍និងបុព្វសិទ្ធិជាច្រើនរបស់សម្តេច ដោយជ្រៀតជ្រែកក្នុងវិស័យ២ដ៏សំខាន់ ៖ គឺក្រសួងការបរទេស និងក្រសួងសេដ្ឋកិច្ច ។ ជាលទ្ធផល ទី១ ៖ រដ្ឋាភិបាលស្រោចស្រង់ជាតិនឹងមិនធ្វើនយោបាយថែចង់ចំពោះពួកយៀកកុងតទៅទៀតទេ ។ ទី២- រដ្ឋាភិបាលដដែលនឹងលុបចោលនូវក្រុមហ៊ុនរដ្ឋទាំងឡាយ ដែលមកទល់ពេលនេះ មាននាទីជាឃ្លាំងប្រាក់សំរាប់«ការរស់នៅដោយសប្បាយ» សំរាប់ស្តេចសីហនុ និងពួកក្រុមហ៊ុនបរិវារទាំងអស់របស់ទ្រង់ ។

នៅថ្ងៃទី៦មករា១៩៧០...សម្តេចសីហនុបានចាកចេញពីប្រទេសកម្ពុជា អស់រយៈពេល៥ឆ្នាំ... ហើយស្តេចយាងត្រឡប់មកវិញ តែនៅពីក្រោយកន្ទុយក្បិនរបស់ពួកខ្មែរក្រហមតែប៉ុណ្ណោះ ។៚